# <u>សេចក្តីថ្លែងការណ៍រួម</u>

## "ចំណាត់ការរហ័ស និងយុត្តិធម៌"

យើងខ្ញុំទាំងអស់គ្នា ជាតំណាងឲ្យអង្គការសង្គមស៊ីវិល ក្រុមយុវវ័យ ធ្វើការរួមគ្នាក្នុងគោលបំណងបញ្ចប់អំពីហិង្សាលើស្ត្រី មានកង្វល់យ៉ាងខ្លាំងក្រោយពីបានទទួលព័ត៌មានស្តីអំពីការធ្វើទារុណកម្មយ៉ាងសាហាវ ឃោរឃៅ ព្រៃផ្សៃ និងអមនុស្សធម៌បំផុតរបស់លោកស្រី **លី ៣៧** ភរិយាលោកឧកញ៉ា **វេងលី តិចឡា** ដែលបានប្រព្រឹត្តទៅលើយុវតី២រូបអស់រយៈពេលជិត១០ឆ្នាំមកនេះ។ លើសពីនេះទៅទៀតយើងខ្ញុំក៏រឹតតែមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីសុវត្ថិភាព និងការទទួលបាននូវភាពយុត្តិធម៌ ត្រឹមត្រូវតាមផ្លូវច្បាប់របស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគាត់ផងដែរ។

ថ្មីៗនេះចាប់តាំងពីថ្ងៃទី ២៨ ខែកុម្ភៈ ដល់ ថ្ងៃទី០១ ខែមីនា នាឆ្នាំ២០១៣ តាមទំព័រការសែត កោះសន្តិភាព កាសែតរស្មីកម្ពុជា កាសែតកម្ពុជាថ្មីនិងបណ្តាសារព័ត៌មានផ្សេងៗទៀតបានចុះផ្សាយជាបន្តបន្ទាប់ករណីរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរមិនអាចទទួលយកបានរបស់លោកស្រីភរិយាលោកឧកញ៉ារូបនេះ។ ជាងនេះទៅទៀតកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ តាមរយៈទំព័រការសែតកម្ពុជាថ្មី បានបង្ហាញនូវការព្យាយាមចរចារ និងគម្រាមកំហែងរបស់ក្រុមគ្រួសារជនសង្ស័យលើជនរងគ្រោះ និងក្រុមគ្រួសារពួកគាត់ឲ្យដោះស្រាយករណីខាងលើ ក្រៅប្រព័ន្ធតុលាការដោយប្រើពាក្យសម្តីថា "គេមានលុយ ចង់ប្តឹងក៏មិនឈ្នះដែរ ប្រយ័ត្នប្រាក់ក៏បង់ ចង់ក៏ដាច់"។

ទង្វើនេះគឺជាករណីនៃការរំលោភបំពានលើសិទ្ធិមនុស្ស ជាពិសេសសិទ្ធិកុមារ សិទ្ធិស្ត្រី យ៉ាងធ្ងន់ធ្ងរ ដែលបានចែងក្នុងអនុសញ្ញាស្តីពិសិទ្ធិកុមារ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។

ដោយមានករណីខាងលើក្នុងនាម អង្គការសង្គមស៊ីវិល រួមជាមួយក្រុមតំណាងយុវវ័យ ទទូចយ៉ាងពេញទំហឹង ដល់គ្រប់ភាគីពាក់ព័ន្ធ និងសារធារណៈជន ជាពិសេសរាជរដ្ឋាភិបាល និងប្រពន្ធ័តុលាការ ក្នុងការធ្វើចំណាត់ការ ដោយឈរលើនីតិវិធីនៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុសញ្ញាអន្តរជាតិផ្សេងៗ និង លើស្មារតី ត្រឹមត្រូវ យុត្តិធម៌ ទាន់ពេលវេលា ដែលធានានូវសុវត្ថិភាពរបស់ជនរងគ្រោះនិងក្រុមគ្រួសារ។

សម្រាប់ព័ត៌មានលំអិត និង បន្ថែម សូមទំនាក់ទំនងមក

-បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍(GADNet)

លោកស្រី អ៊ូ មុំ

លេខទំនាក់ទំនង: ០១៧ ៣៤ ៥៩ ៥៦

-សកម្មយុវនារីកម្ពុជាលើកិច្ចការអាស៊ាន(CYWA)

កញ្ញា សេង រាសី

លេខទំនាក់ទំនង: ០១៧ ៩៣ ៣៣ ៣៦

-ខេមអាស៊ាន (CamASEAN)

កញ្ញា ខាន់ ចាន់វិចិត្រនា

លេខទំនាក់ទំនង: ០៧០ ៧១ ០១ ២៣

-បណ្តាញពង្រឹងសិទ្ធិអំណាចស្ត្រីវ័យក្មេងនៅកម្ពុជា(CYWEN)

កញ្ញា ពិន ម៉ារិន

លេខទំនាក់ទំនង: ០១៧ ៩៣ ៣៣ ៣៦